អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩

# សេចក្តីប្រកាសព័ត៌មាន

ការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) កំពុងចាត់វិធានការពង្រឹង និងរៀបចំសកម្មភាពរបស់ខ្លួនឡើងវិញ ទៅលើផ្នែកកិច្ចការសាធារណៈ ការផ្សព្វផ្សាយ និងអង្គភាពជនរងគ្រោះ។

**ផ្នែកកិច្ចការសាធារណៈ**

លោក **រាជ សម្បត្តិ** ដែលជាមន្ត្រីផ្នែកព័ត៌មានសព្វថ្ងៃ ត្រូវបានតម្លើងតួនាទីជាប្រធានផ្នែកកិច្ចការសាធារណៈ ទទួលខុសត្រូវទៅលើទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយ និងការផ្តល់ព័ត៌មានសាធារណៈស្តីពីកិច្ចការទាំងឡាយរបស់ អ.វ.ត.ក។ លោកស្រីបណ្ឌិត Helen Jarvis ដែលជាប្រធានផ្នែកកិច្ចការសាធារណៈសព្វថ្ងៃ នឹងត្រូវបានផ្លាស់ប្តូរឲ្យទៅដឹកនាំអង្គភាពជនរងគ្រោះ (សូមមើលព័ត៌មានខាងក្រោមបន្ថែម)។ លោក សម្បត្តិ ដែលមានសញ្ញាប័ត្រអនុបណ្ឌិតផ្នែកសារព័ត៌មានពីសាកលវិទ្យាល័យ Columbia ក្នុងទីក្រុងញូវយ៉ក គឺជាសាស្ត្រាចារ្យនៅនាយកដ្ឋានទទួលបន្ទុកផ្នែកប្រព័ន្ធផ្សព្វផ្សាយ និងទំនាក់ទំនងនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងធ្លាប់បម្រើការងារអស់រយៈពេល ១២ ឆ្នាំ ជាមួយការិយាល័យនៃទីភ្នាក់ងារសារព័ត៌មានបារាំង (AFP) ប្រចាំនៅទីក្រុងភ្នំពេញ។

នៅដើមខែមីនា លោក **Lars Olsen** ដែលជាជនជាតិន័រវេ ត្រូវបានជ្រើសតាំងឲ្យកាន់តំណែងថ្មីជាមន្ត្រីទំនាក់ទំនងផ្នែកច្បាប់។ លោក Olsen ទទួលបានសញ្ញាប័ត្រជាន់ខ្ពស់ផ្នែកច្បាប់ពីសាកលវិទ្យាល័យ Oslo និងមានបទពិសោធន៍ជាង ៩ ឆ្នាំ ទៅលើការងារផ្នែកទំនាក់ទំនងសាធារណៈ ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាននៅក្នុងប្រទេសកូសូវ៉ូ និងន័រវេ។ ការទទួលខុសត្រូវចម្បងរបស់គាត់នឹងធានាឲ្យមានសុក្រិតភាព គុណភាព ភាពស៊ីសង្វាក់គ្នា និងភាពទាន់ពេលវេលានៃព័ត៌មានទាក់ទងនឹងផ្នែកច្បាប់ដែលចេញផ្សាយជាសាធារណៈ

ដោយ អ.វ.ត.ក ពិសេស ផ្នែកឯកសារតុលាការនៅក្នុងគេហទំព័ររបស់ អ.វ.ត.ក។ រហូតទាល់តែមានការតែងតាំងមន្ត្រីថ្មីផ្នែកកិច្ចការសាធារណៈដើម្បីជំនួសលោក Peter Foster ដែលការតែងតាំងនេះកំពុងតែដំណើរការនៅឡើយ នោះលោក Olsen ក៏នឹងបម្រើការងារជាអ្នកនាំពាក្យរបស់ UNAKRT ទៅតាមតម្រូវការផងដែរ។

លោក **ឌឹម សុវណ្ណារុំ** ត្រូវបានតែងតាំងជាមន្ត្រីថ្មីផ្នែកសារព័ត៌មាន។ លោក ឌឹម សុវណ្ណារុំ មានសញ្ញាប័ត្រជាន់ខ្ពស់ផ្នែកសារព័ត៌មានមកពីសាលាជាន់ខ្ពស់ទីក្រុងលីល ប្រទេសបារាំង និងសញ្ញាប័ត្រអនុបណ្ឌិតផ្នែកការទូត និងយុទ្ធសាស្ត្រមកពីមជ្ឈមណ្ឌលសិក្សាផ្នែកការទូត និងយុទ្ធសាស្ត្រនៅទីក្រុងប៉ារីស ប្រទេសបារាំង និងជាអតីតអ្នកសារព័ត៌មានប្រចាំទូរទស្សន៍ និងជាពិធីករក្នុងនាទី Rendez-vous អស់រយៈពេលប្រាំមួយឆ្នាំ ដែលជាកម្មវិធីផ្នែកកិច្ចការភាសាបារាំងសព្វថ្ងៃរបស់ ទ.ទ.ក និងជាសាស្ត្រាចារ្យផ្នែកសារព័ត៌មាននៅក្នុងនាយកដ្ឋានភាសាបារាំងនៃវិទ្យាស្ថានភាសាបរទេស នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

**ការផ្សព្វផ្សាយ**

ការងារផ្សព្វផ្សាយរបស់ អ.វ.ត.ក នឹងត្រូវបានធ្វើឲ្យមានសុខដុមនីយកម្ម និងប្រសើរឡើងយ៉ាងខ្លាំង។ សូមអរគុណចំពោះការផ្តល់ថវិកាទាំងតាមរយៈថវិកាស្នូលថ្មី និងតាមរយៈការផ្តល់ថវិកាដោយសប្បុរស ពីសំណាក់រដ្ឋាភិបាលប្រទេសអាល្លឺម៉ង់ តាមរយៈ GTZ។ លោកស្រីបណ្ឌិត Helen Jarvis នឹងបន្តត្រួតពិនិត្យលើការងារនេះ។ លោក **នូ កាស៊ី** ត្រូវបានជ្រើសរើសដោយការប្រឡងប្រជែង ជាអ្នកសម្របសម្រួលកម្មវិធីផ្សព្វផ្សាយ ដោយនាំយកនូវបទពិសោធន៍ផ្តល់ប្រឹក្សារបស់គាត់អស់រយៈពេល ៣០ ឆ្នាំ មកកាន់ អ.វ.ត.ក ក្នុងនាមជនរងគ្រោះដោយសារឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងអាចបញ្ចេញមតិជាជនរងគ្រោះផ្ទាល់ដោយការដាក់ក្នុងពន្ធនាគារពីសំណាក់ខ្មែរក្រហម។ លោក នូ កាស៊ី គឺជាអតីតរដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌ និងមានតួនាទីជាច្រើននៅក្នុងវិស័យរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលនានា។

**អង្គភាពជនរងគ្រោះ**

លោកស្រីបណ្ឌិត **Helen Jarvis** នឹងត្រូវបានផ្លាស់ប្តូរឲ្យធ្វើជាប្រធានអង្គភាពជនរងគ្រោះ។ លោកស្រីបណ្ឌិត Jarvis បានចូលរួមពាក់ព័ន្ធតាំងពីឆ្នាំ ១៩៩៩ នៅក្នុងដំណើរការនៃការបង្កើត អ.វ.ត.ក បន្ទាប់ពីការបំពេញអាជីពជាអ្នកសិក្សាស្រាវជ្រាវ និងអនុវត្តជាក់ស្តែងនៅក្នុងវិស័យគ្រប់គ្រងព័ត៌មាន រួមទាំងធ្លាប់ធ្វើ

ជាទីប្រឹក្សាផ្នែកឯកសារសម្រាប់កម្មវិធីស្តីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ដែលបានបង្កើតមជ្ឈមណ្ឌលឯកសារកម្ពុជា។

យើងសូមថ្លែងអំណរគុណចំពោះការរួមចំណែកពីសំណាក់លោកស្រី **គាត ឫទ្ធិ** ដែលបានប្រកាសលាលែងពី អ.វ.ត.ក ក្រោយពីការកាន់តួនាទីជាប្រធានអង្គភាពជនរងគ្រោះអស់រយៈពេល ១៥ ខែមក ដែលនៅពេលនោះលោកស្រីបានដឹកនាំការបង្កើតអង្គភាពថ្មីនេះ ដោយមានការទទួលខុសត្រូវចំពោះការគាំទ្រដល់ជនរងគ្រោះពីឧក្រិដ្ឋកម្មនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ពិសេស អ្នកដែលមានបំណងដាក់ពាក្យបណ្តឹង ឬចង់ក្លាយជាដើមបណ្តឹងរដ្ឋប្បវេណី។

តួនាទីមួយចំនួនទៀតកំពុងស្ថិតនៅក្នុងដំណើរការបំពេញឡើងវិញ ដើម្បីពង្រឹងដល់មុខងាររបស់អង្គភាពជនរងគ្រោះ ទាក់ទងនឹងដំណើរការនៃការដាក់ពាក្យបណ្តឹង និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ការជួយ និងការគាំទ្រដល់ដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងការធ្វើជាតំណាងផ្លូវច្បាប់ ព្រមទាំងការរៀបចំអនុសាសន៍លើការដាក់បញ្ចូលជាក្រុមដែលអាចធ្វើទៅបាន នៃដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សំណុំរឿង ០០២។ ព័ត៌មានបន្ថែមទៀតលើការវិវឌ្ឍន៍ទាំងនេះ នឹងត្រូវបានផ្តល់ជូននៅពេលក្រោយ។ ក្រោយពីមានការយល់ព្រមពីសំណាក់មន្ត្រីតុលាការក្នុងកិច្ចប្រជុំពេញអង្គរួចមក មានការព្យាករណ៍ថា អង្គភាពជនរងគ្រោះនឹងផ្លាស់ប្តូរឈ្មោះរបស់ខ្លួនទៅជា ផ្នែកគាំពារជនរងគ្រោះ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖


លោកស្រីបណ្ឌិត Helen Jarvis

ប្រធានផ្នែកកិច្ចការសាធារណៈ, អ.វ.ត.ក

ទូរសព្ទដៃលេខ: +៨៥៥-១២ ៤៨៨ ១៣៤

ទូរសារលេខ: +៨៥៥-២៣ ២១៩ ៨៤១

អ៊ីមែល: helen.jarvis@eccc.gov.kh

លោក រាជ សម្បត្តិ

មន្ត្រីផ្នែកសារព័ត៌មាន, អ.វ.ត.ក

ទូរសព្ទដៃលេខ +៨៥៥-១២ ៤៨៨ ១៥៦

ទូរសារលេខ: +៨៥៥-២៣ ២១៩ ៨៤១
អ៊ីម៉ែល: reach.sambath@eccc.gov.kh

លោក Lars Olsen
មន្ត្រីផ្នែកទំនាក់ទំនងច្បាប់, អ.វ.ត.ក
ទូរសព្ទដៃលេខ: +៨៥៥ (0) ១២ ៤៨៨ ០២៣
ទូរសព្ទលើតុ: +៨៥៥ (0) ២៣ ២១៩ ៨១៤ ext. 6169
អ៊ីម៉ែល: olsenl@un.org